**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ១៥៤ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០ ១៤

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រង និងទទួលស្គាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលដៅអភិវឌ្ឍ និងពង្រឹងប្រព័ន្ធ និងគុណភាពអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដើម្បីកសាងសមត្ថភាពអ្នកឯកទេសវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម-សេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងទៅអនាគតនៅក្នុងព្រះរាជាណាចក្រកម្ពុជា តំបន់ និងសកលលោក។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងដូចតទៅ៖

- អភិវឌ្ឍសមត្ថភាព និងគុណវុឌ្ឍិរបស់អ្នកឯកទេសវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច
- ជំរុញឱ្យមានការទទួលស្គាល់កម្រិត និងគុណភាពនៃការអប់រំបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍កម្ពុជាក្នុងសហគមន៍អាស៊ាន តំបន់ និងសកលលោក
- សម្រួលដល់ការធ្វើបម្លាស់ទីរបស់ទីអ្នកឯកទេសវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចនៅក្នុងសហគមន៍អាស៊ាន តំបន់ និងសកលលោក
- រួមចំណែកការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពគ្របដណ្ដប់លើសាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ផ្នែកទី២

## សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលបង្កើតឡើងដោយផ្នែកសាធារណៈ

**ប្រការ៤.-**

សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលបង្កើតឡើងដោយផ្នែកសាធារណៈ ត្រូវសហការផ្ដល់នូវព័ត៌មាន ស្ថិតិដែលពាក់ព័ន្ធនឹងការបណ្ដុះបណ្ដាល និងឯកសារមួយចំនួន តាមការស្នើសុំរបស់ក្រសួងទេសចរណ៍ ជាអាទិ៍កម្មវិធីសិក្សា បញ្ជីរាយនាមសាស្ត្រាចារ្យ និងគ្រូបង្រៀន ជាដើម។

**ប្រការ៥.-**

សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលបង្កើតឡើងដោយផ្នែកសាធារណៈ ត្រូវសហការ និងសម្របសម្រួលជាមួយក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃសាលាវិជ្ជាជីវៈទេសចរណ៍លើការអនុវត្តកម្មវិធីសិក្សា សម្ភារៈបរិក្ខារ និងគរុកោសល្យបណ្ដុះបណ្ដាល។

## ផ្នែកទី៣

## ការបង្កើត និងចុះបញ្ជិកាសាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលបង្កើតឡើងដោយផ្នែកឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល

**ប្រការ៦.-**

គ្រប់សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងអស់ ត្រូវទទួលបានការអនុញ្ញាតពីក្រសួងទេសចរណ៍ជាមុន តាមរយៈការស្នើសុំបង្កើតសាលា។ គំរូពាក្យសុំបង្កើតសាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

ការអនុញ្ញាតដែលចេញដោយក្រសួងទេសចរណ៍ មិនធ្វើឱ្យសាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងអស់រួចផុតពីកាតព្វកិច្ចក្នុងការចុះបញ្ជី ឬទទួលការអនុញ្ញាតពីក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

**ប្រការ៧.-**

គ្រឹះស្ថានអប់រំដទៃទៀត ដែលទទួលបានការអនុញ្ញាតដោយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ហើយមានបំណងពង្រីកសេវាអប់រំរបស់ខ្លួនលើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ត្រូវសុំការអនុញ្ញាតពីក្រសួងទេសចរណ៍ តាមរយៈការស្នើសុំការចុះបញ្ជិកា។ គំរូពាក្យសុំចុះបញ្ជិកា មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៨.-**

ដើម្បីទទួលបានការអនុញ្ញាតចេញដោយក្រសួងទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងអស់ ត្រូវបំពេញលក្ខខណ្ឌចាំបាច់មួយចំនួន ជាអាទិ៍៖

ក- ត្រូវមានទីស្នាក់ការរបស់ខ្លួន ដែលមានអាស័យដ្ឋានច្បាស់លាស់ និងមានបុគ្គលិកបម្រើការងារគ្រប់គ្រាន់។

ខ- ត្រូវមានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលមានទំហំសមស្រប និងសម្បទាគ្រប់គ្រាន់ ដោយរួមមាន៖

- អគារដែលបំពាក់ដោយឧបករណ៍ និងសម្ភារៈបរិក្ខារសម្រាប់ការងារបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ និងភាសាស្របតាមស្តង់ដាមុខជំនាញវិជ្ជាជីវៈទេសចរណ៍ និងតម្រូវការទីផ្សារការងារក្នុងវិស័យទេសចរណ៍ក្នុងស្រុក តំបន់ និងពិភពលោក
- បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌មុខជំនាញវិជ្ជាជីវៈទេសចរណ៍ និងក្រមប្រតិបត្តិមុខជំនាញវិជ្ជាជីវៈទេសចរណ៍របស់ខ្លួន ដែលមានការទទួលស្គាល់ដោយក្រសួងទេសចរណ៍
- ទីកន្លែងក្នុងអគារទាំងអស់ត្រូវមានភាពស្អាត និងប្រកបដោយសុវត្ថិភាព ដែលអនុវត្តតាមផែនការបទដ្ឋានស្តីពីសំណង់អគារ សុវត្ថិភាពអគ្គីភ័យ ពន្ធ ច្បាប់ និងបទប្បញ្ញត្តិដ៏ទៃទៀត ដែលទាក់ទងទៅនឹងសកម្មភាព ទីបរិវេណ និងបរិក្ខារផ្សេងៗទៀត។

គ- ត្រូវមានគ្រូ សាស្ត្រាចារ្យ និងអ្នកឯកទេសវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ដែលមានបទពិសោធន៍ សមត្ថភាពគ្រប់គ្រាន់សម្រាប់ការបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាពជាតិ និងអន្តរជាតិ និងតម្រូវការការងារក្នុងវិស័យទេសចរណ៍។

ឃ- ត្រូវចុះកិច្ចសន្យាជាមួយនឹងក្រសួងទេសចរណ៍អំពីកាតព្វកិច្ច និងនីតិវិធីនៃការប្រតិបត្តិការងារបណ្តុះបណ្តាលមុខវិជ្ជាជីវៈទេសចរណ៍។

ង- ត្រូវមានកម្មវិធីសិក្សាស្របតាមស្តង់ដាកម្មវិធីសិក្សាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ជាតិ និងអាស៊ាន។

ច- ត្រូវមានតំណាងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលមានគុណវុឌ្ឍិ និងវិញ្ញាបនបត្រជំនាញវិជ្ជាជីវៈទេសចរណ៍ បទពិសោធន៍ និងចំណេះដឹងគ្រប់គ្រាន់ ។

ឆ- ត្រូវអនុវត្តតាមស្តង់ដា តម្រូវការបច្ចេកទេស និងប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ស្របតាមស្តង់ដាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ជាតិ និងអាស៊ាន។

**ប្រការ៩.-**

លក្ខខណ្ឌទាំងឡាយដែលមានកំណត់ក្នុងពាក្យស្នើសុំបង្កើត ឬចុះបញ្ជិកាសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ អាចនឹងត្រូវបានកែប្រែក្នុងករណីចាំបាច់។

## ផ្នែកទី៤
## ភារកិច្ចរបស់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
## ដែលបង្កើតឡើងដោយផ្នែកឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល

**ប្រការ១០.-**

សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ត្រូវសហការជាមួយក្រសួងទេសចរណ៍ក្នុងការរៀបចំដំណើរការអប់រំបណ្តុះបណ្តាលអ្នកឯកទេសវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច អោយស្របតាមស្តង់ដាសមត្ថភាពកម្រិតជាតិ អាស៊ាន និងពិភពលោក។

**ប្រការ១១.-**

សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ត្រូវសហការជាមួយក្រសួងទេសចរណ៍ក្នុងការរៀបចំការជ្រើសរើសសិស្សឱ្យចូលរៀន និងការប្រលងបញ្ចប់វគ្គសិក្សាក្នុងសាលារបស់ខ្លួន។ រាល់វិញ្ញាសារសម្រាប់ការប្រឡងចាំបាច់ត្រូវមានការត្រួតពិនិត្យ និងទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**ប្រការ១២.-**

សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ត្រូវបំពេញកាតព្វកិច្ច ដូចខាងក្រោម៖

ក- ត្រូវអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដែលពាក់ព័ន្ធទៅនឹងក្រមសីលធម៌វិជ្ជាជីវៈសកលសម្រាប់វិស័យទេសចរណ៍របស់អង្គការ UNWTO និងលក្ខខណ្ឌនានាសម្រាប់ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច។

ខ- ត្រូវផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចរបស់ខ្លួនស្របតាមស្តង់ដាសមត្ថភាពជាតិ កម្មវិធី វគ្គបណ្តុះបណ្តាល និងប្រអប់បណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ដែលត្រូវបានរៀបចំ តាមដាន គ្រប់គ្រង និងត្រួតពិនិត្យដោយក្រសួងទេសចរណ៍។

គ- ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ០៨ នៃប្រកាសនេះ។

ឃ- ត្រូវសម្របសម្រួលជាមួយក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃសាលាវិជ្ជាជីវៈទេសចរណ៍លើការអនុវត្តកម្មវិធីសិក្សា សម្ភារៈបរិក្ខារបណ្តុះបណ្តាល និងគរុកោសល្យបណ្តុះបណ្តាល។

ង- ត្រូវសហការជាមួយនឹងក្រសួងទេសចរណ៍ក្នុងដំណើរការអង្កេត ត្រួតពិនិត្យលើការអនុវត្តច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈសកលសម្រាប់វិស័យទេសចរណ៍របស់អង្គការ UNWTO និងការអនុវត្តសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចរបស់សាលារបស់ខ្លួន។

ច- ត្រូវទទួលស្គាល់ និងសហការជាមួយនឹងក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធក្នុងដំណើរការត្រួតពិនិត្យ វាយតម្លៃ និងផ្តល់វិញ្ញាបនបត្រជំនាញវិជ្ជាជីវៈទេសចរណ៍ដល់អ្នកជំនាញទេសចរណ៍ ដែលបានបំពេញតាមស្តង់ដាសមត្ថភាពជាតិ។

ឆ- ការពារប្រយោជន៍ជាតិ និងប្រយោជន៍ទេសចរណ៍ ជាពិសេសចូលរួមចំណែកគាំទ្រដល់ការអភិវឌ្ឍជំនាញ និងធ្វើឲ្យការបណ្តុះបណ្តាលមានលទ្ធភាពផ្តល់សមត្ថភាព គុណវុឌ្ឍិដល់សិស្ស និស្សិត និងអ្នកឯកទេសវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច។

ជ- ត្រូវមានការចុះបញ្ជីត្រឹមត្រូវ និងមានសមត្ថភាពហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ដល់ដំណើរការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច។

ឈ- ត្រូវផ្តល់ជាលាយលក្ខណ៍អក្សរដល់ក្រសួងទេសចរណ៍ក្នុងរយៈពេល ០២ សប្តាហ៍បន្ទាប់ពីមានការផ្លាស់ប្តូរចំណុចពិស្តារណាមួយ ដែលទាក់ទងទៅនឹងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍របស់ខ្លួន។

ញ- ត្រូវសហការផ្តល់ព័ត៌មាន និងស្ថិតិដែលពាក់ព័ន្ធទៅនឹងជំនាញវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចដល់ក្រសួងទេសចរណ៍ ព្រមទាំងសហការជាមួយក្រសួង សំដៅធ្វើការអភិវឌ្ឍជំនាញវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចឱ្យកាន់តែមានភាពល្អប្រសើរឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ផ្នែកទី៥

## ការត្រួតពិនិត្យ និងវាយតម្លៃសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលបង្កើតឡើងដោយផ្នែកឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល

**ប្រការ១៣.-**

សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងអស់ នឹងត្រូវបានធ្វើការត្រួតពិនិត្យ និងវាយតម្លៃជារៀងរាល់ឆ្នាំ ដោយក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរបស់ក្រសួងទេសចរណ៍ ក្នុងគោលបំណងពង្រឹងគុណភាពអប់រំវិជ្ជាជីវៈទេសចរណ៍។ ការត្រួតពិនិត្យ និងការវាយតម្លៃ នឹងត្រូវបានជូនដំណឹងជាមុនដោយក្រសួងទេសចរណ៍។

**ប្រការ១៤.-**

ការត្រួតពិនិត្យ និងវាយតម្លៃ ត្រូវធ្វើឡើងស្របទៅនឹងគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យ និងការវាយ-តម្លៃកម្មវិធីសិក្សា សម្ភារៈបរិក្ខារបណ្តុះបណ្តាល និងគរុកោសល្យបណ្តុះបណ្តាលដែលរៀបចំឡើងដោយក្រសួងទេសចរណ៍។

**ប្រការ១៥.-**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃទាំងអស់ ត្រូវបង្ហាញអត្តសញ្ញាណបណ្ណមុខងារ និងបណ្ណបេសកម្ម ឬលិខិតអនុញ្ញាតឲ្យបំពេញបេសកម្មមុននឹងចាប់ផ្តើមធ្វើការត្រួតពិនិត្យ និងវាយតម្លៃ។

**ប្រការ១៦.-**

រាល់ការចុះត្រួតពិនិត្យ និងវាយតម្លៃ អាចមានការចូលរួមពីសំណាក់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ នឹងអ្នកជំនាញទេសចរណ៍ជាតិ និងអន្តរជាតិ ដើម្បីសម្រួលដល់ដំណើរការ និងប្រសិទ្ធិភាពនៃការចុះត្រួតពិនិត្យ និងវាយតម្លៃ។

**ប្រការ១៧.-**

ប្រសិនបើមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ ពិនិត្យរកឃើញថាមានការរំលោភលើបទប្បញ្ញត្តិនៃច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈសកលសម្រាប់វិស័យទេសចរណ៍របស់អង្គការ UNWTO និងខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវក្នុងកម្រិតស្រាល នោះមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ នឹងធ្វើការណែនាំដល់អ្នកគ្រប់គ្រងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ឲ្យធ្វើការបំពេញ និងកែតម្រូវឡើងវិញ។ ក្នុងករណីធ្ងន់ធ្ងរ មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ ត្រូវរាយការណ៍មកក្រសួងទេសចរណ៍ដើម្បីចាត់វិធានការណ៍សមស្របតាមនីតិវិធីច្បាប់។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ១៨.-**

សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលបង្កើតឡើងដោយផ្នែកឯកជន ឬអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណា ដែលប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទទួលទណ្ឌកម្ម ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាក ឬបិទសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ជាបណ្តោះអាសន្ន
- ការបិទសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ជាស្ថាពរ។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**ប្រការ១៩.-**

សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលបង្កើតឡើងដោយផ្នែកឯកជន ឬអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណា ដែលត្រូវបានបង្កើតមុនប្រកាសនេះចូលជាធរមាន និងមិនទាន់មានការអនុញ្ញាតពីក្រសួងទេសចរណ៍ ត្រូវធ្វើការស្នើសុំចុះបញ្ជិកានៅក្រសួងទេសចរណ៍ក្នុងរយៈពេលបី (០៣) ខែ បន្ទាប់ពីប្រកាសនេះចូលជាធរមាន។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ២០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២១.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធានគ្រប់នាយកដ្ឋាន និងប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

***កន្លែងទទួល៖***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*
- *ដូចមាត្រា ២១*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ឧបសម្ព័ន្ធទី១៖ ពាក្យសុំបង្កើតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

## ពាក្យសុំបង្កើតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ .............................................. ភេទ .......... កើតថ្ងៃទី ........ ខែ ........ ឆ្នាំ .......... មានអាស័យដ្ឋាននៅផ្ទះលេខ.................... ផ្លូវ........................ភូមិ.........................ឃុំ/សង្កាត់ .............................. ខណ្ឌ/ក្រុង/ស្រុក.............................. រាជធានី/ខេត្ត ...............................។

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**កម្មវត្ថុ** ៖ សំណើសុំបង្កើតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានឈ្មោះថា "........................ ......................................................................" អក្សរកាត់ជាភាសាខ្មែរ "................" ជាភាសាអង់គ្លេស "..................................................................................." អក្សរកាត់ជាភាសាអង់គ្លេស "..................." ។

**យោង** ៖ ប្រកាសលេខ.... ចុះថ្ងៃទី..... ខែ....... ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងទទួលស្គាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីរួមចំណែកក្នុងការអប់រំបណ្តុះបណ្តាលអ្នកឯកទេសវិជ្ជាជីវៈផ្នែកទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ខ្ញុំបាទ/នាងខ្ញុំ សូមគោរពស្នើសុំការអនុញ្ញាតបង្កើតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានឈ្មោះថា ...................................................................... ដែលមានអាស័យដ្ឋាន ផ្ទះលេខ.............. ផ្លូវលេខ ................ ភូមិ ........................... ឃុំ/សង្កាត់ ........................ ខណ្ឌ/ក្រុង/ស្រុក .............................. រាជធានី/ខេត្ត...............................។

**សូមគោរពជូនភ្ជាប់មកជាមួយនូវ÷**

**១. ឯកសាររដ្ឋបាល**

១.១. លិខិតអនុញ្ញាតចេញដោយអាជ្ញាធរដែនដី (បញ្ជាក់ខាងខ្នង)................................................ ១ច្បាប់

១.២. លិខិតអនុញ្ញាតសាងសងចេញដោយក្រសួង ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ចំពោះសំណង់ថ្មី................................................................ ១ច្បាប់

១.៣. កិច្ចសន្យាអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីទេសចរណ៍ និងច្បាប់ពាក់ព័ន្ធរបស់រដ្ឋ.................. ១ច្បាប់

១.៤. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់គណៈគ្រប់គ្រង........................................ ១ច្បាប់

១.៥. រូបថត (៤x៦) របស់គណៈគ្រប់គ្រង.......................................................... ៣សន្លឹក

១.៦. បទបញ្ជាផ្ទៃក្នុង.......................................................................... ១ច្បាប់

**២. ធនធានមនុស្ស**

២.១. បញ្ជីរាយនាមគណៈគ្រប់គ្រងសាលា........................................................................... ១ច្បាប់

២.២. បញ្ជីរាយនាមសាស្ត្រាចារ្យ និងគ្រូ.............................................................................. ១ច្បាប់

២.៣. បញ្ជីរាយនាមបុគ្គលិក........................................................................................... ១ច្បាប់

**៣. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសម្ភារៈបរិក្ខារ**

៣.១. បញ្ជីទំហំផ្ទៃដី អគារ រោងជាង បន្ទប់ពិសោធន៍ សាលប្រជុំ................................................ ១ច្បាប់

៣.២. បញ្ជីសម្ភារៈបរិក្ខាររោងជាង មន្ទីរពិសោធន៍.................................................................. ១ច្បាប់

**៤. ដំណើរការសិក្សា**

៤.១.កម្មវិធីសិក្សា.......................................................................................................... ១ច្បាប់

៤.២.យន្តការនៃការជ្រើសរើសសិស្សចូលរៀន ការប្រឡងបញ្ចប់ និងការវាយតម្លៃការបណ្តុះបណ្តាល.១ច្បាប់

៤.៣.បទបញ្ញាផ្សេងៗទៀតប្រសិនបើមាន................................................................................ ១ច្បាប់

ក្រោយពីទទួលបានការអនុញ្ញាត និងបង្កើតរួចហើយ សាលានេះនឹងស្ថិតនៅក្រោមការសម្របសម្រួល និងត្រួតពិនិត្យរបស់ក្រសួងទេសចរណ៍។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុញ្ញាតឲ្យខ្ញុំបាទ/នាងខ្ញុំ បង្កើតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានឈ្មោះថា ..................................................... ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ............................ ថ្ងៃទី..... ខែ.......... ឆ្នាំ២០......

ក្រសួងទេសចរណ៍

ឧបសម្ព័ន្ធទី២៖ ពាក្យសុំចុះបញ្ជិកាសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

## ពាក្យសុំចុះបញ្ជិកាសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ .............................................. ភេទ .......... កើតថ្ងៃទី ........ ខែ ........ ឆ្នាំ .......... មានអាស័យដ្ឋាននៅផ្ទះលេខ.....................ផ្លូវ.......................ភូមិ.........................ឃុំ/សង្កាត់ ............................ ខណ្ឌ/ក្រុង/ស្រុក............................... រាជធានី/ខេត្ត .................................។

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**កម្មវត្ថុ** ៖ សំណើសុំចុះបញ្ជិកាសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានឈ្មោះថា “.................. ..................................................................” អក្សរកាត់ជាភាសាខ្មែរ “...............” ជាភាសាអង់គ្លេស “...........................................................................................” អក្សរកាត់ជាភាសាអង់គ្លេស “..................” ។

**យោង** ៖ប្រកាសលេខ.... ចុះថ្ងៃទី..... ខែ...... ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងទទួលស្គាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីរួមចំណែកក្នុងការអប់រំបណ្តុះបណ្តាលអ្នកឯកទេសវិជ្ជាជីវៈផ្នែកទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ខ្ញុំបាទ/នាងខ្ញុំ សូមគោរពស្នើសុំការអនុញ្ញាតចុះបញ្ជិកាសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានឈ្មោះថា ............................................................................ ដែលមានអាស័យដ្ឋាន ផ្ទះលេខ............. ផ្លូវលេខ ................ ភូមិ .......................... ឃុំ/សង្កាត់ ......................... ខណ្ឌ/ក្រុង/ស្រុក ............................. រាជធានី/ខេត្ត......................................។

**សូមគោរពជូនភ្ជាប់មកជាមួយនូវ៖**

**១. ឯកសាររដ្ឋបាល**

- ១.១. លិខិតបង្កើតគ្រឹះស្ថានសិក្សាចេញដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ.............................. ១ច្បាប់
- ១.២. កិច្ចសន្យាអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីទេសចរណ៍ និងច្បាប់ពាក់ព័ន្ធរបស់រដ្ឋ...................... ១ច្បាប់
- ១.៣. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់គណៈគ្រប់គ្រង.............................. ១ច្បាប់
- ១.៤. រូបថត (៤x៦) របស់គណៈគ្រប់គ្រង.............................. ៣សន្លឹក
- ១.៥.បទបញ្ជាផ្ទៃក្នុង.............................. ១ច្បាប់

**២. ធនធានមនុស្ស**

- ២.១. បញ្ជីរាយនាមគណៈគ្រប់គ្រងសាលា.............................. ១ច្បាប់
- ២.២. បញ្ជីរាយនាមសាស្ត្រាចារ្យ និងគ្រូ.............................. ១ច្បាប់
- ២.៣. បញ្ជីរាយនាមបុគ្គលិក.............................. ១ច្បាប់

**៣. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសម្ភារៈបរិក្ខារ**

៣.១. បញ្ជីទំហំផ្ទៃដី អគារ រោងជាង បន្ទប់ពិសោធន៍ សាលប្រជុំ........................................................ ១ច្បាប់

៣.២. បញ្ជីសម្ភារៈបរិក្ខាររោងជាង មន្ទីរពិសោធន៍........................................................................ ១ច្បាប់

**៤. ដំណើរការសិក្សា**

៤.១.កម្មវិធីសិក្សា........................................................................................................ ១ច្បាប់

៤.២.យន្តការនៃការជ្រើសរើសសិស្សចូលរៀន ការប្រឡងបញ្ចប់ និងការវាយតម្លៃការបណ្តុះបណ្តាល.១ច្បាប់

៤.៣.បទបញ្ញាផ្សេងៗទៀតប្រសិនបើមាន........................................................................ ១ច្បាប់

ក្រោយពីទទួលបានការអនុញ្ញាត និងចុះបញ្ជិកាហើយ ផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍របស់សាលានេះ នឹងស្ថិតនៅក្រោមការសម្របសម្រួល និងត្រួតពិនិត្យរបស់ក្រសួងទេសចរណ៍។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុញ្ញាតឲ្យខ្ញុំបាទ/នាងខ្ញុំ បានធ្វើការចុះបញ្ជិកាសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានឈ្មោះថា .................................................ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ............................ ថ្ងៃទី..... ខែ......... ឆ្នាំ២០......

ព្រះរាជាណាចក្រកម្ពុជា ក្រសួង ទេសចរណ៍